# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ · សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ១០៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់ របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** គោលបំណង

អនុក្រឹត្យនេះមានគោលបំណងបង្កើត និងកំណត់នូវឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់របស់មន្ត្រីនៃគណៈកម្មការមូលបត្រកម្ពុជាដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាភ្នាក់ងារនគរបាលយុត្តិធម៌។ ឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់នេះត្រូវប្រើប្រាស់សម្រាប់បំពេញការងារ។

### ជំពូកទី ២
### ឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់
### ផ្នែកទី ១
### ឯកសណ្ឋាន

**មាត្រា ២.-** ថ្នាក់នៃឯកសណ្ឋាន

ឯកសណ្ឋានរបស់មន្ត្រីនៃគណៈកម្មការមូលបត្រកម្ពុជាដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវកំណត់ជា ០២ (ពីរ) ថ្នាក់ ដូចខាងក្រោម ៖

១-ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីផ្សេងទៀត នៃគណៈកម្មការមូលបត្រកម្ពុជា ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។

២-ថ្នាក់ភ្នាក់ងារ ដែលជាមន្ត្រីនៃគណៈកម្មការមូលបត្រកម្ពុជា ទទួលបាននីតិសម្បទាជាភ្នាក់ងារនគរបាលយុត្តិធម៌។

**មាត្រា ៣.-** ឯកសណ្ឋានថ្នាក់លេខ ១

ឯកសណ្ឋានរបស់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីផ្សេងទៀត នៃគណៈកម្មការមូលបត្រកម្ពុជា ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវកំណត់ដូចខាងក្រោម ÷

**១- ចំពោះបុរស**

- អាវដៃខ្លីពណ៌ប្រផេះក្រម៉ៅ កបើក ថ្មេរខុប ប៉ូលស្មា ជីបចង្កេះ មានហោប៉ៅបួនដែលហោប៉ៅពីរខាងលើដេរបត់ផ្នត់កណ្តាល គម្របរាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្តាល គម្របរាងស្លឹកពោធិ៍ និងឡេវមានត្រារូបព្រះសង្ហារពណ៌មាស (មានភ្ជាប់គំរូក្នុងឧបសម្ព័ន្ធទី ១)។
- អាវដៃវែងពណ៌ប្រផេះក្រម៉ៅ កបើក ថ្មេរខុប ប៉ូលស្មា ជីបភ្លីខាងមុខពីរ មានឡេវធំពណ៌មាសពីក្រោមរហូតដល់លើ មានហោប៉ៅបួនដែលហោប៉ៅពីរខាងលើដេរបត់ផ្នត់កណ្តាល គម្របរាងស្លឹកពោធិ៍ ឡេវធំពណ៌មាស ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្តាល គម្របរាងចតុកោណកែង ឡេវធំពណ៌មាស។ ផ្នែកខាងក្រោយ មានជីបភ្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានឆែកចំកណ្តាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌ស ដៃវែង ភ្ជាប់ក្រវ៉ាត់កពណ៌ក្រហមក្រម៉ៅ (មានភ្ជាប់គំរូក្នុងឧបសម្ព័ន្ធទី ២)។
- ខោជើងវែងដេរអំពីសាច់ក្រណាត់ និងពណ៌ដូចអាវ ចង្កេះដេរត ថ្មេរបង្កប់ ជីបភ្លីខាងមុខពីរ មានហោប៉ៅបួនដែលហោប៉ៅពីរខាងក្រោយដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្មេរ។
- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ។
- ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ។

**២- ចំពោះស្ត្រី**

- អាវម៉ូតដូចបុរស ប៉ុន្តែ កអាវមានរាងជាកអាវរបស់ស្ត្រី។
- ខោម៉ូតដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ ឬសំពត់ហ៊ីបសាច់ក្រណាត់ និងពណ៌ដូចអាវ កាត់ស្រុងក្រោមជង្គង់ ឆែកក្រោយ រូតចំហៀង។
- ស្បែកជើងឃ្លុប កខ្លី មានកែង ស្បែកពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ។
- ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ។

**មាត្រា ៤.-** ឯកសណ្ឋានថ្នាក់លេខ ២

ឯកសណ្ឋានរបស់ភ្នាក់ងារ ដែលជាមន្ត្រីនៃគណៈកម្មការមូលបត្រកម្ពុជា ទទួលបាននីតិសម្បទាជាភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវកំណត់ដូចខាងក្រោម ÷

**១- ចំពោះបុរស**

- អាវដៃខ្លី ឬអាវដៃវែង ពណ៌ប្រផេះក្រម៉ៅ កឌុប ប៉ូលស្វា ហោប៉ៅពីរដេរបត់ផ្នត់កណ្ដាល គម្របរាងស្លឹកពោធិ៍ កាត់ស្រុងជើងត្រង់ដាក់ក្នុងខោ (មានភ្ជាប់គំរូក្នុងឧបសម្ព័ន្ធទី ៣)។
- អាវដៃវែងពណ៌ប្រផេះក្រម៉ៅ កបើក ថ្នេរឌុប ប៉ូលស្វា ជីបភ្លឺខាងមុខពីរ មានខ្សែរធំពណ៌ប្រាក់ពីក្រោមរហូតដល់លើ មានហោប៉ៅបួនដែលហោប៉ៅពីរខាងលើដេរបត់ផ្នត់កណ្ដាល គម្របរាងស្លឹកពោធិ៍ ខ្សែរធំពណ៌ទឹកប្រាក់ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្ដាល គម្របរាងចតុកោណកែង ខ្សែរធំពណ៌ប្រាក់។ ផ្នែកខាងក្រោយមានជីបភ្លឺចំនួនពីរ ឆ្វេងមួយ ស្ដាំមួយ និងមានផែកចំកណ្ដាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌ស ដៃវែង ភ្ជាប់ក្រវ៉ាត់ក ពណ៌ក្រហមក្រម៉ៅ។ អាវដៃវែងនេះពាក់សម្រាប់ពិធីការតែប៉ុណ្ណោះ។
- ខោជើងវែងដេរអំពីសាច់ក្រណាត់ និងពណ៌ដូចអាវ ចង្កេះដេរត ថ្នេរបង្កប់ ជីបភ្លឺខាងមុខពីរ មានហោប៉ៅបួនដែលហោប៉ៅពីរខាងក្រោយដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ។
- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ។
- ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ។

**២- ចំពោះស្ត្រី**

- អាវដៃខ្លី ឬអាវដៃវែង ពណ៌ដូចបុរស កឌុប ប៉ូលស្វា ហោប៉ៅពីរដេរបត់ផ្នត់កណ្ដាល គម្របរាងស្លឹកពោធិ៍ ជីបចង្កេះ។
- ខោម៉ូតដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ ឬសំពត់ហ៊ើបសាច់ក្រណាត់ និងពណ៌ដូចអាវ កាត់ស្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង។
- ស្បែកជើងឃ្លុប កខ្លី មានកែង ស្បែកពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ។
- ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ។

**មាត្រា ៥.-** មួកកាស្កែត

មួកកាស្កែតត្រូវបានរៀបចំជា ០៦ (ប្រាំមួយ) ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ ថ្នាក់អគ្គនាយក ថ្នាក់អគ្គនាយករង ថ្នាក់ប្រធាននាយកដ្ឋាន-អនុប្រធាននាយកដ្ឋាន ថ្នាក់ប្រធានការិយាល័យ-អនុប្រធាន

ការិយាល័យ ថ្នាក់មន្ត្រីផ្សេងទៀតដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងថ្នាក់ភ្នាក់ងារ (មានភ្ជាប់គំរូក្នុងឧបសម្ព័ន្ធទី ៤)។

១-ថ្នាក់អគ្គនាយក ៖ មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចសម្លៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប់វ័ណ្ឌ មានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់ ៧,៨ សង់ទីម៉ែត្រ ទទឹង ៦,៨ សង់ទីម៉ែត្រ ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារ មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសដល់ជើងមួក និងខាងក្រោមក្បាច់ មានប៉ាក់វ័ណ្ឌពណ៌មាសពីលើក្រណាត់ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ព្រមទាំងនៅចុងខ្សែវ័ណ្ឌទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ហាពណ៌មាស។ ខាងក្រោមនៃប៉ាក់វ័ណ្ឌផ្នែកខាងមុខ មានក្បាំងពណ៌ខ្មៅនៅលើក្បាំងមានប៉ាន់ក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្នែងក្របីធំដល់ជើងមួក។

២-ថ្នាក់អគ្គនាយករង ៖ មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចសម្លៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប់វ័ណ្ឌ មានភ្ជាប់រូបព្រះសង្ហារពណ៌មាស ទំហំកម្ពស់ ៧,៨ សង់ទីម៉ែត្រ ទទឹង ៦,៨ សង់ទីម៉ែត្រ ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារ មានប៉ាក់វ័ណ្ឌពណ៌មាសពីលើក្រណាត់ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ព្រមទាំងនៅចុងខ្សែវ័ណ្ឌទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាស។ ខាងក្រោមនៃប៉ាក់វ័ណ្ឌផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ាន់ក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្នែងក្របីធំដល់ជើងមួក។

៣-ថ្នាក់ប្រធាននាយកដ្ឋាន-អនុប្រធាននាយកដ្ឋាន ៖ មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចសម្លៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប់វ័ណ្ឌ មានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់ ៧,៨ សង់ទីម៉ែត្រ ទទឹង ៦,៨ សង់ទីម៉ែត្រ ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារ មានកណ្តាប់វ័ណ្ឌធ្វើពីក្រណាត់ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វ័ណ្ឌផ្នែកខាងមុខ មានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងមុខក្រោមកណ្តាប់វ័ណ្ឌដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួក មានប៉ាន់ក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្នែងក្របីដល់ជើងមួក។

៤-ថ្នាក់ប្រធានការិយាល័យ-អនុប្រធានការិយាល័យ ៖ មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចសម្លៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប់វ័ណ្ឌ មានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់ ៧,៨ សង់ទីម៉ែត្រ ទទឹង ៦,៨ សង់ទីម៉ែត្រ ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារ មានកណ្តាប់វ័ណ្ឌធ្វើពីក្រណាត់ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វ័ណ្ឌផ្នែកខាងមុខ មានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងមុខក្រោមកណ្តាប់វ័ណ្ឌដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាន់ក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្នែងក្របី ដោយចុងសងខាងទុកចន្លោះ ៤ សង់ទីម៉ែត្រពីជើងមួក។

៥-ថ្នាក់មន្ត្រីផ្សេងទៀតដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ៖ មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចសម្លៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្ដាប់វ័ណ្ឌ មានភ្ជាប់រូបព្រះសង្ហារពណ៌មាស ទំហំកម្ពស់ ៧,៨ សង់ទីម៉ែត្រ ទទឹង ៦,៨ សង់ទីម៉ែត្រ ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារ មាន កណ្ដាប់វ័ណ្ឌ ធ្វើពីក្រណាត់ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ។ ខាងក្រោមកណ្ដាប់វ័ណ្ឌផ្នែកខាងមុខ មាន ក្បាំងពណ៌ខ្មៅ ដែលនៅជាយក្បាំងព័ទ្ធជុំវិញដោយខ្សែឆ្នូតពណ៌មាស។ ផ្នែកខាងមុខ ក្រោមកណ្ដាប់វ័ណ្ឌ ដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាង ភ្ជាប់ដោយឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួក គ្មានប៉ានក្បាច់ភ្ជីទេសទេ។

៦-ថ្នាក់ភ្នាក់ងារ ៖ មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចសម្លៀកបំពាក់ ដែលផ្នែកខាងមុខលើកណ្ដាប់វ័ណ្ឌ មានភ្ជាប់រូបព្រះសង្ហារពណ៌ប្រាក់ទំហំកម្ពស់ ៧,៨ សង់ទីម៉ែត្រ ទទឹង ៦,៨ សង់ទីម៉ែត្រ ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្ដាប់វ័ណ្ឌធ្វើពីក្រណាត់ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ។ ខាងក្រោមកណ្ដាប់វ័ណ្ឌផ្នែកខាងមុខ មានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងមុខក្រោមកណ្ដាប់វ័ណ្ឌដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ហារពណ៌ប្រាក់។ នៅលើក្បាំងមួក គ្មានប៉ានក្បាច់ភ្ជីទេសទេ។

## ផ្នែកទី ២
## សញ្ញាសក្តិ

**មាត្រា ៦.-** ថ្នាក់សញ្ញាសក្តិ

សញ្ញាសក្តិស្មា ៖ ខ្នាតសញ្ញាសក្តិស្មាត្រូវមានបាតក្រោមប្រវែង ៦ សង់ទីម៉ែត្រ បណ្ដោយពីលើដល់បាតក្រោមប្រវែង ១៣ សង់ទីម៉ែត្រ និងមានទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤,៧ សង់ទីម៉ែត្រ មានរាងកោងជាមុំទាល។ សញ្ញាសក្តិស្មាត្រូវបានរៀបចំជា ០៨ (ប្រាំបី) ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់អគ្គនាយក ថ្នាក់អគ្គនាយករង ថ្នាក់ប្រធាននាយកដ្ឋាន ថ្នាក់អនុប្រធាននាយកដ្ឋាន ថ្នាក់ប្រធានការិយាល័យ ថ្នាក់អនុប្រធានការិយាល័យ ថ្នាក់មន្ត្រីផ្សេងទៀតដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និង ថ្នាក់ភ្នាក់ងារ (មានភ្ជាប់គំរូក្នុងឧបសម្ព័ន្ធទី ៥ ដល់ឧបសម្ព័ន្ធទី ១២)។

១-ថ្នាក់អគ្គនាយក ៖ មានផ្ទៃពណ៌ខៀវទឹកប៊ិច ក្បាច់ភ្ជីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ គ.ម.ក ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំធំទ្រខាងក្រោម មានរូបសញ្ញាសម្គាល់របស់គណៈកម្មាធិការប្រព្រឹត្តិ កម្ពុជារាងមូលពណ៌មាសនៅចំកណ្ដាល និងមានរូបព្រះសង្ហារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។

២- ថ្នាក់អគ្គនាយករង : មានផ្ទៃពណ៌ខៀវទឹកប៊ិច ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ "គ.ម.ក" ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំតូចទ្រខាងក្រោម មានរូបសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជារាងមូលពណ៌មាស និងមានរូបព្រះសង្ខារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។

៣- ថ្នាក់ប្រធាននាយកដ្ឋាន : មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំធំ ដែលនៅលើក្បាច់នេះមានប៉ាក់អក្សរ "គ.ម.ក" ពណ៌មាស ដែលនៅលើអក្សរមានរូបសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជារាងមូលពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធួរវេញ ៣ ខ្សែពណ៌មាសព័ទ្ធជុំវិញពីខាងក្រៅ។

៤- ថ្នាក់អនុប្រធាននាយកដ្ឋាន : មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច ដែលនៅលើក្បាច់នេះមានប៉ាក់អក្សរ "គ.ម.ក" ពណ៌មាស ដែលនៅលើអក្សរមានរូបសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជារាងមូលពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធួរវេញ ២ ខ្សែពណ៌មាសព័ទ្ធជុំវិញពីខាងក្រៅ។

៥- ថ្នាក់ប្រធានការិយាល័យ : មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច ដែលនៅលើក្បាច់នេះ មានប៉ាក់អក្សរ "គ.ម.ក" ពណ៌មាស ដែលនៅលើអក្សរមានរូបសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជារាងមូលពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធួរវេញ ១ ខ្សែពណ៌មាសព័ទ្ធជុំវិញពីខាងក្រៅ។

៦- ថ្នាក់អនុប្រធានការិយាល័យ : មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច ដែលនៅលើក្បាច់នេះមានប៉ាក់អក្សរ "គ.ម.ក" ពណ៌ប្រាក់ ដែលនៅលើអក្សរមានរូបសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជារាងមូលពណ៌ប្រាក់នៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធួរវេញ ១ ខ្សែពណ៌មាសព័ទ្ធជុំវិញពីខាងក្រៅ។

៧- ថ្នាក់មន្ត្រីផ្សេងទៀតដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ : មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ទំហំតូច ដែលនៅលើក្បាច់នេះមានប៉ាក់អក្សរ "គ.ម.ក" ពណ៌ប្រាក់ ដែលនៅលើអក្សរមានរូបសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជា

រាងមូលពណ៌ប្រាក់នៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌ប្រាក់នៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ ១ ខ្សែពណ៌មាសព័ទ្ធជុំវិញពីខាងក្រៅ។

៨-ថ្នាក់ភ្នាក់ងារ ៖ មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្ករពណ៌ប្រាក់ទំហំតូច ដែលនៅលើក្បាច់នេះមានចុះអក្សរ "គ.ម.ក" ពណ៌ប្រាក់ ដែលនៅលើអក្សរមានរូបសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជារាងមូលពណ៌ប្រាក់នៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌ប្រាក់នៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ ១ ខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញពីខាងក្រៅ។

## ផ្នែកទី ៣
## សញ្ញាសម្គាល់

**មាត្រា ៧.-** សញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជា

សញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជា មានរាងមូល និងមានរូបសញ្ញា ព្រមទាំងអត្ថន័យដូចខាងក្រោម (មានភ្ជាប់គំរូក្នុងឧបសម្ព័ន្ធទី ១៣) ៖

១-រូបសញ្ញា

- រូបហង្សពណ៌មាស
- រូបរង្វង់មូលដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ
- រូបស្លឹកឈើ
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើដោយអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" និងព័ទ្ធជារង្វង់នៅផ្នែកខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA"។

២- អត្ថន័យនៃរូបសញ្ញា

- រូបហង្សពណ៌មាស ៖ តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកត្រួតពិនិត្យ គ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌។
- រូបរង្វង់មូលដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ៖ តំណាងឱ្យការចំណេញ ខាត ឬការឡើង ចុះនៃដំណើរការទីផ្សារ។

- រូបហង្សពណ៌មាសឈរលើរង្វង់មូល ដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងជាន់លើផ្ទៃពណ៌ប្រផេះ បង្ហាញថាការចំណេញ ខាត ឬការឡើង ចុះនៃដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់គណៈកម្មការមូលបត្រកម្ពុជា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌។
- រូបស្លឹកឈើ ៖ លទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**មាត្រា ៨.-** ស្លាកសញ្ញាសម្គាល់

ស្លាកសញ្ញាសម្គាល់របស់មន្ត្រីនៃគណៈកម្មការមូលបត្រកម្ពុជា មានដូចខាងក្រោម (មានភ្ជាប់គំរូក្នុងឧបសម្ព័ន្ធទី ១៤)៖

១-ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ ៖ មានរូបហង្សពណ៌មាសធ្វើអំពីលោហធាតុ និងក្រួមេពណ៌មាស។ សញ្ញាសម្គាល់នេះប្រើសម្រាប់ថ្នាក់អនុប្រធានការិយាល័យឡើងដែលទទួលបានទីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។ ចំពោះមន្ត្រីផ្សេងទៀតដែលទទួលបានទីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារ ស្លាកសញ្ញាមានលក្ខណៈដូចខាងលើដែរ ប៉ុន្តែធ្វើអំពីលោហធាតុ និងក្រួមេពណ៌ប្រាក់។

២-ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ ៖ មានទម្រង់មូលផ្ទៃខាងលើ និងខាងក្រោមពណ៌ខៀវ កណ្តាលពណ៌ក្រហម ដែលមានប្រាសាទអង្គរពណ៌សនៅចំកណ្តាល ព័ទ្ធជុំវិញដោយអក្សរ "ព្រះរាជាណាចក្រកម្ពុជា" នៅផ្នែកខាងលើ និងអក្សរ "គណៈកម្មការមូលបត្រកម្ពុជា" នៅផ្នែកខាងក្រោម ដោយតួស្លាកសញ្ញានេះធ្វើពីក្រណាត់ដែលមានអង្កត់ផ្ចិត ៨ សង់ទីម៉ែត្រ សម្រាប់ដេរភ្ជាប់នៅដើមដៃអាវស្តាំ ក្រោមថ្នេរស្មា ៥ សង់ទីម៉ែត្រ ដោយកំណត់យកក្តិធ្វើជាចំណុចកណ្តាល។

៣-ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់បំពាក់លើតម្រុយហោប៉ៅអាវស្តាំ ៖ ជាស្លាកសញ្ញាដែលមានតួស្លាកសញ្ញាធ្វើពីជ័រប្លាស្ទិចមានបណ្តោយ ១០ សង់ទីម៉ែត្រ ទទឹង ២ សង់ទីម៉ែត្រ មានផ្ទៃពណ៌ខៀវ គូសបន្ទាត់ពណ៌មាសខណ្ឌចែក និងមានតួអក្សរពណ៌មាស។ តួស្លាកសញ្ញាត្រូវបានចែកចេញជាពីរផ្នែក គឺផ្នែកខាងឆ្វេងមានបណ្តោយ ២,៥ សង់ទីម៉ែត្រ ដោយមានសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជា ដែលមានផ្ទៃខាងលើ និងខាងក្រោម ពណ៌ខៀវ កណ្តាលពណ៌ក្រហម និងមានអត្តលេខសម្គាល់មន្ត្រីសាមីនៅពីក្រោមសញ្ញាសម្គាល់នោះ ហើយផ្នែកខាងស្តាំមានបណ្តោយ ៧,៥ សង់ទីម៉ែត្រ មានអក្សរពីរជួរ ដែលជួរទីមួយសរសេរឈ្មោះមន្ត្រីសាមីជាអក្សរខ្មែរ មានកម្ពស់អក្សរ ០,៥ សង់ទីម៉ែត្រ និងជួរទីពីរសរសេរឈ្មោះជាអក្សរឡាតាំងមានកម្ពស់អក្សរ ០,៣ សង់ទីម៉ែត្រ។

៤-ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែរគម្របហោប៉ៅអាវស្តាំ : មានតួស្លាកសញ្ញាធ្វើពីលោហៈធាតុរាងមូលប៉ោង មានផ្ទៃខាងលើ និងខាងក្រោមពណ៌ខៀវ កណ្តាលពណ៌ក្រហម ហើយមានសញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជា មានអង្កត់ផ្ចិត ៥ សង់ទីម៉ែត្រ ភ្ជាប់ដោយបន្ទះស្បែក សម្រាប់ពាក់លើហោប៉ៅអាវខាងស្តាំ។

**មាត្រា ៩.-** របបនៃឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់

ឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ដល់មន្ត្រីម្នាក់ៗ ចំនួន ០២ (ពីរ) កំប្លេ សម្រាប់ប្រើប្រាស់ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ។

**មាត្រា ១០.-** មន្ត្រីទទួលបន្ទុកគ្រប់គ្រង

ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនៃគណៈកម្មការមូលបត្រកម្ពុជា មានភារកិច្ចទទួលខុសត្រូវលើការគ្រប់គ្រង ការចែកជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

**មាត្រា ១១.-** កាតព្វកិច្ចរបស់មន្ត្រី

ក្នុងពេលបំពេញប្រតិបត្តិការ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

## ជំពូកទី ៣

## ទោសប្បញ្ញត្តិ

**មាត្រា ១២.-** ទោសប្បញ្ញត្តិ

ជនណាក្លែងបន្លំ ដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ ឬសញ្ញាសម្គាល់ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-** បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ឧបសម្ព័ន្ធទី ៦

អនុក្រឹត្យលេខ ១០៧ អនក្រ.បក

ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១

ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់

របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

.....

ឯកសណ្ឋានសម្រាប់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន

អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ

និងមន្ត្រីផ្សេងទៀត ដែលទទួលបានគតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌



## ឧបសម្ព័ន្ធទី ២

អនុក្រឹត្យលេខ ១០៧ អនក្រ បក

ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១

ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់

របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

.....

### ឯកសណ្ឋានសម្រាប់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីផ្សេងទៀត ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌



## ឧបសម្ព័ន្ធទី ៣

## អនុក្រឹត្យលេខ

## ចុះថ្ងៃទី ខែ ឆ្នាំ ២០១១

## ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់

## របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

### ឯកសណ្ឋានសម្រាប់ភ្នាក់ងារ



**ឧបសម្ព័ន្ធទី ៤**

**អនុក្រឹត្យលេខ [illegible]**

**ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១**

**ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់**

**របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា**

.....

**មួកការស្កេត**



**មួកការស្កេត សម្រាប់អគ្គនាយក**



**មួកការស្កេត សម្រាប់អគ្គនាយករង**



**មួកការស្កេត សម្រាប់ប្រធាននាយកដ្ឋាន - អនុប្រធាននាយកដ្ឋាន**



**មួកការស្កេត សម្រាប់ប្រធានការិយាល័យ - អនុប្រធានការិយាល័យ**



មួកការស្កេត សម្រាប់មន្ត្រីផ្សេងទៀតដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌



មួកការស្កេត សម្រាប់ភ្នាក់ងារ

## ឧបសម្ព័ន្ធទី ៥

អនុក្រឹត្យលេខ

ចុះថ្ងៃទី ខែ ឆ្នាំ ២០១១

## ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់

## របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

.....

### សញ្ញាសក្តិសម្រាប់អគ្គនាយក



ឧបសម្ព័ន្ធទី ៦

អនុក្រឹត្យលេខ

ចុះថ្ងៃទី ខែ ឆ្នាំ ២០១១

ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់

របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

សញ្ញាសក្តិសម្រាប់អគ្គនាយករង



## ឧបសម្ព័ន្ធទី ៧

**អនុក្រឹត្យលេខ ១០៧៥.អនក្រ.បក**

**ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១**

**ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់**

**របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា**

* * * * *

### សញ្ញាសក្តិសម្រាប់ប្រធាននាយកដ្ឋាន



**ឧបសម្ព័ន្ធទី ៨**

**អនុក្រឹត្យលេខ** ១០៧ .អនក្រ .បក

**ចុះថ្ងៃទី** ០៦ **ខែ** មិថុនា **ឆ្នាំ ២០១១**

**ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់**

**របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា**

. . . . .

**សញ្ញាសក្តិសម្រាប់អនុប្រធាននាយកដ្ឋាន**



**ឧបសម្ព័ន្ធទី ៩**

**អនុក្រឹត្យលេខ ១០៧.អនក្រ.បក**

**ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១**

**ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់**

**របស់មន្ត្រី ថ្នាក់ទាវនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា**

* * * * *

**សញ្ញាសក្តិសម្រាប់ប្រធានការិយាល័យ**



ឧបសម្ព័ន្ធទី ១០

អនុក្រឹត្យលេខ [illegible]

ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

ស្ដីពីឯកសណ្ឋាន សញ្ញាសក្ដិ និងសញ្ញាសម្គាល់

របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

.....

## សញ្ញាសក្តិសម្រាប់អនុប្រធានការិយាល័យ



ឧបសម្ព័ន្ធ ១១

អនុក្រឹត្យលេខ

ចុះថ្ងៃទី ខែ ឆ្នាំ ២០១១

ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់

របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា

.....

## សញ្ញាសក្តិសម្រាប់មន្ត្រីផ្សេងទៀតដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌



**ឧបសម្ព័ន្ធទី ១២**

**អនុក្រឹត្យលេខ ១០៧ អនក្រ.បក**

**ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១**

**ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់**

**របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា**

.....

**សញ្ញាសក្តិសម្រាប់ភ្នាក់ងារ**



**ឧបសម្ព័ន្ធទី ១៣**

**អនុក្រឹត្យលេខ ១០៧.អនក្រ.បក**

**ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១**

**ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់**

**របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា**

*****

**សញ្ញាសម្គាល់របស់គណៈកម្មការមូលបត្រកម្ពុជា**



**ឧបសម្ព័ន្ធទី ១៤**

**អនុក្រឹត្យលេខ ១៤០ អនក្រ.បក**

**ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១**

**ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់**

**របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា**

.....

**ស្លាកសញ្ញាសម្គាល់**




ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់បំពាក់លើគម្របហោប៉ៅអាវស្តាំ



ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរលើឡេវគម្របហោប៉ៅអាវស្តាំ



ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ

ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ

**មាត្រា ១៤.-** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យ ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
ដូចមាត្រា ១៤ "ដើម្បីអនុវត្ត"
រាជកិច្ច
ឯកសារ-កាលប្បវត្តិ

**បានយកសេចក្ដីជម្រាបជូន**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**